ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការគោល

## សម្រាប់ការអប់រំបច្ចេកទេស
## នៅមធ្យមសិក្សាទុតិយភូមិ

(២០១៥-២០១៩)

ខែកុម្ភៈ ឆ្នាំ២០១៥

ឧបត្ថម្ភការបោះពុម្ពដោយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

# មាតិកា

ទំព័រ

**មាតិកា** .......... i
**អារម្ភកថា** .......... iii
**ពាក្យកាត់ និងអក្សរសម្គាល់** .......... iv
**ជំពូកទី១ សេចក្តីផ្តើម** .......... ១
**ជំពូកទី២ សាវតារ** .......... ២
២.១ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀន និងសម្ភារបរិក្ខារ .......... ៣
២.២ ការចូលរៀន ផ្នែកអប់រំបច្ចេកទេស .......... ៤
២.៣ គ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស .......... ៤
២.៤ ការវិភាគស្ថានភាពបច្ចុប្បន្ន .......... ៥
២.៥ ការប្រើប្រាស់ធនធាន និងការចូលរួមពីអ្នកពាក់ព័ន្ធ .......... ៥
២.៦ ក្របខណ្ឌគតិយុត្តគាំទ្រ និងយុទ្ធសាស្ត្រសម្រាប់ការអប់រំបច្ចេកទេស .......... ៦
**ជំពូកទី៣ ចក្ខុវិស័យ បេសកកម្ម គោលបំណង និងយុទ្ធសាស្ត្រ** .......... ៨
៣.១ ចក្ខុវិស័យ .......... ៨
៣.២ បេសកកម្ម .......... ៨
៣.៣ គោលបំណង .......... ៨
៣.៤ យុទ្ធសាស្ត្រ .......... ៨
**ជំពូកទី៤ យុទ្ធសាស្ត្រ និងយុទ្ធសាស្ត្ររង** .......... ៩
៤.១ យុទ្ធសាស្ត្រទី ១ ការបង្កើតក្របខណ្ឌគតិយុត្តគាំទ្រប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស .......... ១០
យុទ្ធសាស្ត្ររង ១.១ ការកសាងលិខិតបទដ្ឋានគតិយុត្ត .......... ១០
យុទ្ធសាស្ត្ររង ១.២ ការបង្កើតយន្តការគ្រប់គ្រង និងការគាំទ្រ ផ្នែកអប់រំបច្ចេកទេស .......... ១០
យុទ្ធសាស្ត្ររង ១.៣ ការបង្កើតផ្នែកស្រាវជ្រាវ និងការអភិវឌ្ឍ .......... ១១
៤.២ យុទ្ធសាស្ត្រទី ២ ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស .......... ១២
យុទ្ធសាស្ត្ររង ២.១ ការកែលម្អប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស .......... ១២
យុទ្ធសាស្ត្ររង ២.២ ការពង្រីក និងការពង្រឹងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស .......... ១៣
យុទ្ធសាស្ត្ររង ២.៣ ការគាំទ្រ និងដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស .......... ១៣
៤.៣ យុទ្ធសាស្ត្រទី ៣ ការរៀបចំនិងការកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស .......... ១៥
យុទ្ធសាស្ត្ររង ៣.១ ការរៀបចំ និងកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស .......... ១៥
យុទ្ធសាស្ត្ររង ៣.២ ការរៀបចំផែនការបង្រៀន និងរៀន ផ្នែកអប់រំបច្ចេកទេស .......... ១៥
យុទ្ធសាស្ត្ររង ៣.៣ ការពិនិត្យឡើងវិញជាប្រចាំនូវកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេសក្នុងគោលដៅធានានូវភាពច្នៃប្រឌិត ផ្អែកតាមបម្រែបម្រួលសង្គម .......... ១៥
៤.៤ យុទ្ធសាស្ត្រទី ៤ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការបំពាក់សម្ភារបរិក្ខារ

ផ្នែកអប់រំបច្ចេកទេស ........................................................................ ១៧
យុទ្ធសាស្ត្ររង ៤.១ ការសាងសង់បន្ទប់រៀន បន្ទប់ពិសោធន៍ និងអគាររោងជាង ..................... ១៧
យុទ្ធសាស្ត្ររង ៤.២ ការបំពាក់សម្ភារបរិក្ខារ ផ្នែកអប់រំបច្ចេកទេសស្របតាមស្តង់ដារតាមជំនាញនីមួយៗ ........................................................................ ១៧
៤.៥ យុទ្ធសាស្ត្រទី ៥ ការបណ្តុះបណ្តាល ការលើកកម្ពស់សមត្ថភាព និងគុណវុឌ្ឍិគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ........................................................................ ១៨
យុទ្ធសាស្ត្ររង ៥.១ ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស និងមន្ត្រីគ្រប់គ្រង........................................................................ ១៨
យុទ្ធសាស្ត្ររង ៥.២ ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស.................... ១៨
យុទ្ធសាស្ត្ររង ៥.៣ ការលើកទឹកចិត្តគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ..................................... ១៩
៤.៦ យុទ្ធសាស្ត្រទី ៦ ការទទួលស្គាល់ និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស.................. ២០
យុទ្ធសាស្ត្ររង ៦.១ ការកសាងប្រព័ន្ធទទួលស្គាល់ និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស ..... ២០
យុទ្ធសាស្ត្ររង ៦.២ ការទទួលស្គាល់ និងគុណវុឌ្ឍិសិស្ស ................................................ ២០
យុទ្ធសាស្ត្ររង ៦.៣ ការបង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស........................................................................ ២១
៤.៧ យុទ្ធសាស្ត្រទី ៧ ការរៀបចំផែនការដើម្បីធានានូវនិរន្តរភាព ផ្នែកអប់រំបច្ចេកទេស................ ២២
យុទ្ធសាស្ត្ររង ៧.១ ការបង្កើតកិច្ចសហប្រតិបត្តិការ រវាងសហគ្រាស សាលារៀន អាជ្ញាធរមូលដ្ឋាន ២២
យុទ្ធសាស្ត្ររង ៧.២ ការបណ្តុះសហគ្រិនភាព និងការប្រកួតប្រជែង.................................. ២២
យុទ្ធសាស្ត្ររង ៧.៣ ការរៀបចំផែនការស្វែងរកថវិកា.................................................... ២៣
យុទ្ធសាស្ត្ររង ៧.៤ ការរៀបចំ និងអនុវត្តកម្មវិធីស្ពានចម្លង ........................................... ២៣
៤.៨ យុទ្ធសាស្ត្រទី ៨ ការបញ្ជ្រាបយេនឌ័រ ........................................................................ ២៤
យុទ្ធសាស្ត្ររង ៨.១ ការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់សមភាពយេនឌ័រ........................... ២៥
យុទ្ធសាស្ត្ររង ៨.២ ការលើកកម្ពស់សមធម៌យេនឌ័រ ផ្នែកអប់រំបច្ចេកទេស............................ ២៥
យុទ្ធសាស្ត្ររង ៨.៣ ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រ .................... ២៦
**ជំពូកទី៥ យុទ្ធសាស្ត្រអាទិភាព និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តផែនការគោល** ........................................................................ ២៧
៥.១ យុទ្ធសាស្ត្រអាទិភាព........................................................................ ២៧
៥.២ ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តផែនការគោល ....................................... ៣១
**ជំពូកទី៦ សេចក្តីសន្និដ្ឋាន**........................................................................ ៣២
**ឧបសម្ព័ន្ធទី១** លទ្ធផលវិភាគគំរូ SWOT Analysis........................................................ ៣៣
**ឧបសម្ព័ន្ធទី២** ការស្ទង់មតិអំពីទស្សនៈការអប់រំគ្រូ ........................................................ ៣៩
**ឧបសម្ព័ន្ធទី៣** របាយការណ៍ការវិភាគតាមគំរូ IPA ........................................................ ៤២
**ឧបសម្ព័ន្ធទី៤** លទ្ធផលវិភាគស្តីពីសមភាពយេនឌ័រតាមគំរូ SWOT Analysis ........................ ៥២
**ឧបសម្ព័ន្ធទី៥** តារាងម៉ាទ្រិកផែនការសកម្មភាពនៃផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ........................................................................ ៥៥

# អារម្ភកថា

ប្រទេសកម្ពុជា មានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ដូចនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវអភិវឌ្ឍជំនាញបច្ចេកទេសដល់យុវជន ដើម្បីបង្កើនឱកាសការងារជំនាញដល់យុវជន ក្នុងការប្រកួតប្រជែងសេដ្ឋកិច្ច នៅពេលប្រទេសកម្ពុជាចូលជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅចុងខែធ្នូឆ្នាំ២០១៥។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញជាយុទ្ធសាស្ត្រ នូវការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងគុណភាពវិស័យអប់រំ ដោយជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ។ ដើម្បីធានាបានការអនុវត្តយុទ្ធសាស្ត្រខាងលើទទួលបានជោគជ័យ ត្រូវរួមគ្នាដោះស្រាយ និងបំពេញភាពខ្វះខាតទាំងឡាយដែលនៅសេសសល់ដូចជា ការកាត់បន្ថយគម្លាតអភិវឌ្ឍ ការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្នែកស្ថាប័នរដ្ឋ ស្ថាប័នឯកជន ទាំងផ្នែកសហគ្រាសខ្នាតតូច និងមធ្យម ដែលទាមទារឲ្យការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំបច្ចេកទេសមានគុណភាព ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់។

ការអភិវឌ្ឍជំនាញរឹង និងជំនាញទន់ដល់យុវជនមានសារៈសំខាន់ណាស់ ដោយធ្វើយ៉ាងណាអភិវឌ្ឍជំនាញដល់យុវជនឲ្យមានលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញាស្មារតី សីលធម៌ គុណតម្លៃ បំណិន និងជំនាញបច្ចេកទេស ក្នុងគោលបំណងឲ្យពួកគេក្លាយជាពលរដ្ឋល្អក្នុងសង្គម ព្រមទាំងចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ និងប្រទេសជាតិស្របតាមចតុស្តម្ភទាំង៤ នៃការអប់រំបច្ចេកទេសគឺ **រៀនដើម្បីធ្វើ ធ្វើដើម្បីរៀន រកប្រាក់ដើម្បីរស់នៅ និងរស់នៅដើម្បីផ្តល់សេវា** ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បុគ្គលិកអប់រំទាំងអស់ អ្នកជំនាញការកូរ៉េ ដែលបានចូលរួមក្នុងការអភិវឌ្ឍផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ។ ឯកសារនេះ មានសារៈសំខាន់ដើម្បីកែលម្អផលិតភាពប្រសិទ្ធភាព និងគុណភាពនៃការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាគ្រប់ស្ថាប័នពាក់ព័ន្ធ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស អង្គការជាតិ អន្តរជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការ ព្រមទាំងគាំទ្រដល់ការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិឲ្យបានជោគជ័យ។

រាជធានីភ្នំពេញថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# ពាក្យកាត់ និងអក្សរសម្គាល់

| | | |
|---|---|---|
| នា. តទវ | = | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| នា. នក | = | នាយកដ្ឋាននីតិកម្ម |
| នា. បល | = | នាយកដ្ឋានបុគ្គលិក |
| នា. បវ | = | នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រិតការ |
| នា. ធគអ | = | នាយកដ្ឋានធានាគុណភាពអប់រំ |
| នា. សណ | = | នាកយកដ្ឋានសំណង់ |
| នា. សទរ | = | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| នា. មចទ | = | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| វិ. ជអ | = | វិទ្យាស្ថានជាតិអប់រំ |
| វិ. ច.ប | = | វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស |
| មន្ទីរ អយក | = | មន្ទីរអប់រំ យុវជន និងកីឡា |

# ជំពូកទី ១
## សេចក្តីផ្តើម

សកលភាវូបនីយកម្ម កំពុងតែធ្វើឲ្យប្រទេសទាំងអស់កាន់តែខិតជិតគ្នាលើគ្រប់វិស័យ ដែលតម្រូវឲ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមចំណែកអភិវឌ្ឍជំនាញដល់យុវជនប្រកបដោយនិរន្តរភាព។

សមាហរណកម្មអាស៊ាននៅចុងឆ្នាំ២០១៥ កម្ពុជាអាចប្រកួតប្រជែងកម្លាំងពលកម្មទីផ្សារការងារតាមរយៈការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)។ ការអប់រំបច្ចេកទេស មានតួនាទីសំខាន់ដែលគួរឲ្យកត់សម្គាល់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរ ក្នុងវិស័យពលកម្មការងារនៅប្រទេសកម្ពុជា។

តាមបរិបទដែលបានលើកឡើងខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំបច្ចេកទេស ដើម្បីផ្តល់ឲ្យយុវជននូវជំនាញបច្ចេកទេសស្របតាមតម្រូវការទីផ្សារ។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អភិវឌ្ឍផែនការគោលសម្រាប់ការអប់រំបច្ចេកទេស កម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេសលើ ០៥ ជំនាញ៖ មេកានិច អគ្គិសនី អេឡិចត្រូនិច កសិកម្ម និងគណនេយ្យ សម្រាប់អនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។

ម្យ៉ាងវិញទៀត ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗ និងសកម្មភាពការងារអប់រំបច្ចេកទេស ដោយផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការងារតម្រង់ទិសវិជ្ជាជីវៈ កម្មវិធីអប់រំបំណិនជីវិត កម្មវិធីស្ពានចម្លង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការប្រឹក្សាអាជីពសម្រាប់សិស្សមធ្យមសិក្សា ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការផ្តល់នូវបំណិន និងជំនាញបច្ចេកទេសវិជ្ជាជីវៈដល់សិស្សងាយស្រួលរកការងារដែលមានប្រាក់កម្រៃខ្ពស់ អាចដោះស្រាយបញ្ហាសេដ្ឋកិច្ចគ្រួសារ សង្គម និងបន្តការសិក្សាពេញមួយជីវិត។

ផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិមាន៖ យុទ្ធសាស្ត្រចំនួន ០៨ និងយុទ្ធសាស្ត្ររងចំនួន ២៤។ យុទ្ធសាស្ត្រទាំងនោះមានដូចជា៖ ការបង្កើតក្របខណ្ឌគតិយុត្តគាំទ្រប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ការរៀបចំនិងការកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបំពាក់សម្ភារបរិក្ខារអប់រំបច្ចេកទេស ការបណ្តុះបណ្តាលនិងការលើកកម្ពស់សមត្ថភាព និងគុណវុឌ្ឍិគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ការទទួលស្គាល់និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស ការរៀបចំផែនការប្រកបដោយនិរន្តរភាព ផ្នែកអប់រំបច្ចេកទេស និងការបញ្ជ្រាបយេនឌ័រ។

# ជំពូកទី ២
## សាវតារ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ការដោះស្រាយបញ្ហាប្រឈម និងតម្រូវការនានា ព្រមទាំងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំបច្ចេកទេស រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាយុទ្ធសាស្ត្រនូវការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងគុណភាពវិស័យអប់រំ ដោយជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស សម្រាប់សិស្សមធ្យមសិក្សាចំណេះទូទៅ ។

ដើម្បីធានាការអនុវត្តយុទ្ធសាស្ត្រខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដោយបញ្ចូលកម្មវិធីអប់រំបច្ចេកទេសទៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សាក្នុងគោលបំណងផ្តល់សេវាអប់រំនូវមុខជំនាញបច្ចេកទេសជាមូលដ្ឋានដល់សិស្សានុសិស្ស ដើម្បីអាចមានលទ្ធភាពចូលប្រកួតប្រជែងក្នុងទីផ្សារការងារ ដែលអាចពង្រីកសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គមបាន។

ឆ្លើយតបទៅនឹងស្មារតីខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកសាងគោលនយោបាយ ស្តីពីការអប់រំបច្ចេកទេស សំដៅពង្រឹង និងពង្រីកការផ្តល់សេវាអប់រំបច្ចេកទេសដល់ប្រជាពលរដ្ឋ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដោយសង្កត់ធ្ងន់លើការផ្តល់សេវាអប់រំបច្ចេកទេសនៅមធ្យមសិក្សា តាមរយៈការបន្ត និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍវិស័យឯកជន សហគមន៍ ព្រមទាំងមាតាបិតាសិស្ស។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីអប់រំពីរផ្នែកគឺ ផ្នែកចំណេះទូទៅ និងផ្នែកបច្ចេកទេស នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដោយផ្សារភ្ជាប់សាលារៀនទៅនឹងការងារ និងការអភិវឌ្ឍអាជីព សម្រាប់ការរៀនពេញមួយជីវិត។ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទាំងនោះ បានអនុវត្តមុខជំនាញផ្សេងៗគ្នា ដូចជា ក្សេត្រសាស្ត្រ បសុវប្បកម្ម អគ្គិសនី អេឡិចត្រូនិច មេកានិច គណនេយ្យ...។ល។

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដែលបាននិងកំពុងអនុវត្តកម្មវិធីពីរផ្នែករួមមាន៖

- វិទ្យាល័យកំពង់ឈើទាល បានចាប់ផ្តើមបណ្តុះបណ្តាលចាប់តាំងពីឆ្នាំ២០០២ លើមុខជំនាញចំនួនបួន៖ អេឡិចត្រូនិច អគ្គិសនី ក្សេត្រសាស្ត្រ និងបសុវប្បកម្ម
- វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន រ៉ូតាខ្សាច់កណ្តាល បានចាប់អនុវត្តការអប់រំបច្ចេកទេសនៅឆ្នាំ២០១២ ដោយបណ្តុះបណ្តាលជំនាញចំនួនពីរ៖ អេឡិចត្រូនិច និងអគ្គិសនី

- វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានចាប់អនុវត្តការអប់រំបច្ចេកទេសនៅឆ្នាំ២០១៣ ដោយបណ្តុះបណ្តាលជំនាញចំនួនពីរៈ អគ្គិសនី និងកេរ្យត្រសាស្ត្រ ។

ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំសម្រាប់ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីអប់រំបច្ចេកទេសនៅក្នុងខែកក្កដា ឆ្នាំ២០១៤។ ដើម្បីធានាបាននូវដំណើរការអប់រំបច្ចេកទេសពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ដោយសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េក្នុងឆ្នាំ២០១៤ កន្លងទៅនេះ។ ចាប់ពីពេលនេះតទៅ ក្រសួងអប់រំ យុវជន និងកីឡា មានផែនការពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឲ្យបានយ៉ាងហោចណាស់ ចំនួន ៧ រាជធានី-ខេត្ត ត្រឹមឆ្នាំ២០១៨ ស្របតាមផែនការគោលសម្រាប់ការអប់រំបច្ចេកទេស។

ដើម្បីលើកកម្ពស់គុណភាពអប់រំបច្ចេកទេសឲ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវតែអភិវឌ្ឍផែនការគោលសម្រាប់ការអប់រំបច្ចេកទេស ដែលឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម ឱកាស និងដំណោះស្រាយស្របទៅនឹងបរិបទសង្គម។ ផ្អែកលើការវិភាគទីផ្សារការងារ និងលទ្ធផលវិភាគតាមគំរូ SWOT Analysis នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េបានធ្វើនៅក្នុងឆ្នាំ២០១៤ (សូមមើលឧបសម្ព័ន្ធ១) ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យឃើញថាប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានស្ថានភាព និងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារ
- អត្រាចូលរៀន និងបញ្ចប់ការសិក្សាមានកម្រិតទាប
- មានការលំបាកក្នុងការជ្រើសរើសគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសដែលមានសមត្ថភាព
- កង្វះខាតប្រសិទ្ធភាព នៃប្រព័ន្ធធានាគុណភាពអប់រំបច្ចេកទេស
- កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជននៅមានកម្រិត។

## ២.១ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀននិងសម្ភារបរិក្ខារ

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានចាត់ទុកថា ជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការអនុវត្តកម្មវិធីឲ្យទទួលបានជោគជ័យ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងនោះរួមមាន អគាររដ្ឋបាល អគារសិក្សា បន្ទប់ពិសោធន៍ រោងជាង អន្តេវាសិកដ្ឋាន និងផ្ទៃដីធំទូលាយសម្រាប់ការប្រតិបត្តិជាក់ស្តែង។ ជាងនេះទៅទៀត ហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់មួយចំនួនទៀតសម្រាប់គាំទ្រដល់ការរៀន និងការបង្រៀន គួរត្រូវគិតគូរដូចជា ទឹក ម៉ាស៊ីន អគ្គិសនី ការអប់រំបច្ចេកទេស និងទីធ្លាសម្រាប់លេង។ល។ ប៉ុន្តែតាមលទ្ធផលនៃការវិភាគតាមគំរូ SWOT Analysis ស្តីពីការគ្រប់គ្រងការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយចំនួនជួបការលំបាកក្នុងការបំពាក់សម្ភារបរិក្ខារ ដែលចាំបាច់ក្នុងការរៀន និងបង្រៀន ដើម្បីទទួលបាននូវជំនាញ និងចំណេះដឹង។

សម្ភារបរិក្ខារនឹងត្រូវបំពាក់គ្រប់មុខវិជ្ជាជំនាញ។ ការកំណត់ស្តង់ដារសម្ភារបរិក្ខារទៅតាមជំនាញនីមួយៗនឹងត្រូវរៀបចំឡើង ដើម្បីធានាថាសិស្សទទួលបានជំនាញចាំបាច់ដូចគ្នាតាមមុខជំនាញនីមួយៗ។ បច្ចុប្បន្ន ការគ្រប់គ្រង ការប្រើប្រាស់ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀន និងសម្ភារបរិក្ខារនៅមានកម្រិតនៅឡើយ។

## ២.២ ការចូលរៀន ផ្នែកអប់រំបច្ចេកទេស

ក្នុងប្រទេសកម្ពុជាមានតែសិស្ស ៣០ភាគរយប៉ុណ្ណោះ ចូលរៀន ផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈរយៈពេលវែង (ជាងមួយឆ្នាំ)។ ចំនួននេះមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារការងារ។ ក្នុងឆ្នាំ ២០១៣ មានសិស្សប្រហែល ៧៥.០០០នាក់ បានចូលរៀនវគ្គសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មាន៦៨ភាគរយ នៃសិស្សបានចូលរៀនមុខវិជ្ជាជំនាញកម្រិតវិញ្ញាបនបត្រ ក្នុងនោះ ៦០ភាគរយបានចូលរៀនមុខវិជ្ជាពាក់ព័ន្ធនឹងកសិកម្ម និងមុខវិជ្ជាផ្សេងៗទៀតរួមមាន កាត់ដេរ ធ្វើម្ហូប និងមេកានិច។

ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ សិស្សចូលរៀនផ្នែកអប់រំបច្ចេកទេសមានចំនួន ៩៥០នាក់ នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសក្នុងខេត្តទាំងបី។ សិស្សចុះឈ្មោះចូលរៀនផ្នែកបច្ចេកទេសនៅមានចំនួនតិចតួចនៅឡើយ បើធៀបនឹងតម្រូវការទីផ្សារការងារ និងការបណ្តុះបណ្តាលបច្ចេកទេសដល់យុវជន។ ជាងនេះទៅទៀត កត្តាសង្គមដែលពុំសូវផ្តល់តម្លៃខាងជំនាញបច្ចេកទេស បានធ្វើឲ្យសិស្សស្ទាក់ស្ទើរ ក្នុងការចូលសិក្សាផ្នែកអប់រំបច្ចេកទេស ជាជាងខាងផ្នែកចំណេះទូទៅ ដែលនេះជាបញ្ហាប្រឈមចម្បងមួយសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ។

## ២.៣ គ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស

ក្រសួងអប់រំ យុវជន និង កីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្តុះបណ្តាលគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស នូវជំនាញពាក់ព័ន្ធ និងអភិវឌ្ឍកម្លាំងពលកម្មទៅតាមតម្រូវការទីផ្សារការងារស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបង្កើនការប្រកួតប្រជែងថ្នាក់ជាតិតាមរយៈ ការផ្តល់ការអប់រំបច្ចេកទេសនូវមុខវិជ្ជាសំខាន់ៗ និងជំនាញបច្ចេកទេសផងដែរ។ បញ្ហាដែលមិនអាចទាក់ទាញបេក្ខជនដែលមានសមត្ថភាពជំនាញច្បាស់លាស់ចូលធ្វើគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ព្រោះបច្ចុប្បន្ននេះ ការឲ្យតម្លៃមកលើអាជីពគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសនៅមានកម្រិត។ និស្សិតដែលបានបញ្ចប់ការសិក្សាផ្នែកបច្ចេកវិទ្យា ឬវិស្វកម្ម មិនចង់បម្រើការងារជាគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសក្នុងវិស័យសាធារណៈទេ ភាគច្រើននិស្សិតទាំងនោះ ស្វែងរកការងារតាមវិស័យឯកជន ក្រុមហ៊ុន សហគ្រាសទៅវិញ។

ការស្ទង់មតិពីតម្រូវការផ្នែកអប់រំបច្ចេកទេស និងចំណង់ចំណូលចិត្តនិស្សិត ដែលចង់ធ្វើជាគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសដោយផ្តោតទៅលើនិស្សិតវិស្វកម្ម ចំនួន ៣៩៨នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកវិទ្យា និងសាកល វិទ្យាល័យន័រតុន បានបង្ហាញថានិស្សិត ចំនួន ៩៧ភាគរយ ឯកភាពថា ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិជាការចាំបាច់ (សូមមើលឧបសម្ព័ន្ធ២)។ ជាចំណុចល្អដែលសិស្ស និស្សិត ចំនួនជាង ៧០ ភាគរយ ចង់ក្លាយជាគ្រូផ្នែកអប់រំបច្ចេកទេសតាមហេតុផលជាក់លាក់ដូចខាងក្រោម៖

- ភាពចាំបាច់នៃការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ( ៩៧ ភាគរយ)
- មានចំណង់ចំណូលចិត្តចង់ក្លាយជាគ្រូ ( ៣១ ភាគរយ)
- ស្រលាញ់អាជីពជាគ្រូបង្រៀន ( ១៩ ភាគរយ)
- ចង់ក្លាយជាមន្ត្រីរាជការ ( ១៦ ភាគរយ)
- មានសមត្ថភាពចិញ្ចឹមជីវិត ( ៩ ភាគរយ)
- មិនមានហេតុផលច្បាស់លាស់ ( ២៦ ភាគរយ)

ដើម្បីផ្តល់នូវសេវាអប់រំបណ្តុះបណ្តាលប្រកបដោយគុណភាព និងអាចទាក់ទាញនិស្សិតដែលចង់ក្លាយជាគ្រូបង្រៀនទាំងនោះបាន ត្រូវពិចារណាលើគុណវុឌ្ឍិគ្រូបង្រៀន និងការលើកទឹកចិត្តគ្រូបង្រៀន ព្រមទាំងកត្តាអាទិភាពមួយចំនួនទៀតដូចជា ការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តផ្លាស់ទៅបង្រៀននៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលខ្វះគ្រូ និងការសាងសង់អន្តេវាសិកដ្ឋាន ដែលមានបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូអប់រំបច្ចេកទេស។

## ២.៤ ការវិភាគស្ថានភាពបច្ចុប្បន្ន

ប្រទេសកម្ពុជាមានកំណើននកម្លាំងពលកម្មខ្ពស់ ជាពិសេសមានចំនួនយុវជនច្រើនជាងប្រទេសមួយចំនួន ក្នុងចំណោមប្រទេសដែលសម្បូរទៅដោយយុវជននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែល៦០ភាគរយនៃចំនួនប្រជាជនសរុប មានអាយុក្រោម ២៤ឆ្នាំ។ នេះអាចចាត់ទុកថា ជាកត្តាដ៏ល្អមួយសម្រាប់ប្រទេសដែលមានចំនួនយុវជនដ៏ច្រើនឈានចូលទៅក្នុងទីផ្សារការងារ។

តាមរយៈលទ្ធផលការវិភាគតាមគំរូ SWOT Analysis (KOICA ឆ្នាំ២០១៤) បានបង្ហាញថា ការអប់រំបច្ចេកទេស ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ នៅមានកង្វះខាតខាងផ្នែកក្របខណ្ឌគុណវុឌ្ឍិដ៏រឹងមាំ ការផ្គត់ផ្គង់ធនធានមនុស្សនៅមានកម្រិត ពុំមានប្រព័ន្ធទទួលស្គាល់ និងធានាគុណភាពការអប់រំបច្ចេកទេសនៅឡើយ។ ជាងនេះទៅទៀត ការផ្សារភ្ជាប់រវាងសាលារៀនទៅនឹងទីផ្សារការងារក៏នៅមានកម្រិត ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុសាលារៀនមិនទាន់រឹងមាំ ព្រមទាំងការចូលរួមរបស់អ្នកពាក់ព័ន្ធក៏នៅមានកម្រិត។ កត្តាទាំងអស់នេះ កម្ពុជាត្រូវសិក្សារៀនសូត្រឲ្យបានស៊ីជម្រៅពីប្រទេសដទៃលើការផ្តល់សេវាអប់រំបច្ចេកទេស។

## ២.៥ ការប្រើប្រាស់ធនធាន និងការចូលរួមពីអ្នកពាក់ព័ន្ធ

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនការបែងចែកថវិកាដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងគុណភាពវិស័យអប់រំ។ ការបែងចែកធនធានដើម្បីគាំទ្រ ផ្នែកអប់រំបច្ចេកទេស និងការប្រមូលផ្តុំការចូលរួមចំណែកពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់នាពេលថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់លើការចំណាយសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ដើម្បីដំណើរការកម្មវិធីការអប់រំបច្ចេកទេសប្រកបដោយនិរន្តរភាព និងគុណភាព វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនីមួយៗ ទទួលបានកញ្ចប់ថវិកាចំនួន ៥០.០០០.០០០រៀល ក្នុងមួយឆ្នាំៗ ៦០០.០០០រៀល សម្រាប់សិស្សម្នាក់ ហើយ ៤០.០០០រៀល ទៀតក្នុងសិស្សម្នាក់ៗសម្រាប់ការធ្វើកម្មសិក្សា (ប្រកាសលេខ ៥០៨ ឆ្នាំ២០១៣)។

មិនតែប៉ុណ្ណោះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការការចូលរួមចំណែកពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តកម្មវិធីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិប្រកបដោយជោគជ័យ។

## ២.៦ ក្របខណ្ឌគតិយុត្តគាំទ្រ និងយុទ្ធសាស្ត្រសម្រាប់ការអប់រំបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្របខណ្ឌគតិយុត្ត និងគោលនយោបាយមួយចំនួនសម្រាប់គាំទ្រសេវាកម្មអប់រំបច្ចេកទេស ការបង្កើនគុណភាពវិស័យអប់រំ និងគាំទ្រអំពីសារៈសំខាន់នៃការបង្កើត និងដាក់ឲ្យដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយទាំងនោះរួមមាន៖

១. ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ មានគោលដៅអភិវឌ្ឍធនធានមនុស្សរបស់ប្រទេស តាមរយៈការផ្តល់នូវឱកាសសិក្សាពេញមួយជីវិតដល់អ្នកសិក្សា លើកកម្ពស់គុណភាពអប់រំ និងបញ្ជាក់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំ ហើយច្បាប់នេះ គ្របដណ្តប់លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផងដែរ។

២. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តកម្មវិធីអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ តាមរយៈគោលនយោបាយសកម្មភាព និងយុទ្ធសាស្ត្រដ៏រឹងមាំ ព្រមទាំងគោលនយោបាយសកម្មភាព និងសូចនាករលទ្ធផលសំខាន់ៗ ទាក់ទងនឹងការអប់រំបច្ចេកទេសដូចខាងក្រោម៖
   - រៀបចំផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅក្នុងឆ្នាំ២០១៤
   - រៀបចំក្របខណ្ឌគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសដែលបង្រៀននៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឲ្យបានត្រឹមឆ្នាំ២០១៤
   - រៀបចំក្របខណ្ឌគតិយុត្ត និងយន្តការ ក្នុងការពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនៅក្នុងឆ្នាំ២០១៥
   - រៀបចំកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងស្តង់ដារកម្មវិធីសិក្សា ទៅតាមតម្រូវការរបស់សហគមន៍ ត្រឹមឆ្នាំ២០១៦
   - រៀបចំគោលការណ៍ ស្តីពីអភិបាលកិច្ចល្អ សម្រាប់ការអប់រំនៅមធ្យមសិក្សាចំណេះទូទៅ និងនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសត្រឹមឆ្នាំ២០១៤
   - ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនឹងមានចំនួន៧ ត្រឹមឆ្នាំ២០១៨
   - ចំនួនសិស្សចូលរៀននៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសកើនឡើងពី ៦១០នាក់ នៅក្នុងឆ្នាំសិក្សា ២០១២-២០១៣ ដល់ ២.០០០នាក់ នៅក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ។

៣. គោលនយោបាយ ស្តីពីការអប់រំបច្ចេកទេសឆ្នាំ២០១៣ បានបង្កើតឡើង ដើម្បីពង្រឹង និងពង្រីកសេវាកម្មអប់រំបច្ចេកទេសដល់ពលរដ្ឋ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។ គោលបំណងនៃគោលនយោបាយនេះមានដូចខាងក្រោម៖
   - អភិវឌ្ឍគ្រឹះស្ថានមធ្យមសិក្សាទៅជាគ្រឹះស្ថានអប់រំបច្ចេកទេសពេញលេញ

- អភិវឌ្ឍជំនាញអប់រំបច្ចេកទេសឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងបរិបទសង្គមកម្ពុជា
- ផ្តល់ឱកាសដល់សិស្សវិទ្យាល័យចំណោះទូទៅ នូវជម្រើសខាង ផ្នែកអប់រំបច្ចេកទេស
- អភិវឌ្ឍគុណភាព និងសមត្ថភាពជំនាញបច្ចេកទេសដល់សិស្សវិទ្យាល័យ
- ប្រមូលផ្តុំធនធានសហគមន៍ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្នុងការចូលរួមចំណែកអភិវឌ្ឍការអប់រំបច្ចេកទេស។

៤. យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងបុគ្គលិកៈ
- អនុវត្តគោលនយោបាយលើកកម្ពស់ជីវភាព
- សិក្សាគោលការណ៍ ស្តីពីប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារអប់រំ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ
- អនុវត្តគោលការណ៍ឲ្យបុគ្គលិកអប់រំបានឡើងកាំប្រាក់បៀវត្សជាប្រចាំនិងជាស្វ័យប្រវត្តិ និងការដំឡើងឋានន្តរសក្តិ
- ពិនិត្យតម្រូវការ និងការផ្គត់ផ្គង់បុគ្គលិកអប់រំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងប្រសិទ្ធភាពនៃការងារតែងតាំងមន្ត្រីគ្រប់គ្រង
- ពង្រឹងការអនុវត្តគោលការណ៍ ស្តីពីការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់បុគ្គលិកអប់រំ។

# ជំពូកទី៣
## ចក្ខុវិស័យ បេសកកម្ម គោលបំណង និងយុទ្ធសាស្ត្រ

### ៣.១ ចក្ខុវិស័យ

សិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេស និងសីលធម៌ល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងបន្តការសិក្សាពេញមួយជីវិត។

### ៣.២ បេសកកម្ម

តម្រង់ទិស លើកកម្ពស់ និងផ្តល់សេវាអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ដោយមានការចូលរួមចំណែកពីអ្នកពាក់ព័ន្ធនានា រួមទាំងដៃគូអភិវឌ្ឍ។

### ៣.៣ គោលបំណង

៣.៣.១ បង្កើតប្រព័ន្ធអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ។

៣.៣.២ បង្កើតស្តង់ដារកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស។

៣.៣.៣ បង្កើត និងពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស តាមស្តង់ដារនៅគ្រប់រាជធានីខេត្ត។

៣.៣.៤ បង្កើនចំនួនសិស្សចូលរៀន ផ្នែកអប់រំបច្ចេកទេស ដើម្បីទទួលបាននូវជំនាញវិជ្ជាជីវៈដែលអាចឲ្យពួកគេរកការងារធ្វើបាន និងចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

### ៣.៤ យុទ្ធសាស្ត្រ

៣.៤.១ ការបង្កើតក្របខណ្ឌគតិយុត្តគាំទ្រប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស

៣.៤.២ ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស

៣.៤.៣ ការរៀបចំ និងកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស

៣.៤.៤ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបំពាក់សម្ភារបរិក្ខារ ផ្នែកអប់រំបច្ចេកទេស

៣.៤.៥ ការបណ្តុះបណ្តាលការលើកកម្ពស់សមត្ថភាព និងគុណវុឌ្ឍិគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស

៣.៤.៦ ការទទួលស្គាល់ និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស

៣.៤.៧ ការរៀបចំផែនការប្រកបដោយនិរន្តរភាព ផ្នែកអប់រំបច្ចេកទេស

៣.៤.៨ ការបញ្ជ្រាបយេនឌ័រ

# ជំពូកទី៤

## យុទ្ធសាស្ត្រ និងយុទ្ធសាស្ត្ររង




ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ ផ្តោតទាំងស្រុងលើលទ្ធផលសិក្សារបស់សិស្ស ដែលទាមទារនូវធាតុគាំទ្រមួយចំនួនរួមមាន ក្របខណ្ឌគតិយុត្តសម្រាប់គាំទ្រដល់ប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ដើម្បីឈានដល់គោលដៅបង្កើតកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេស។ ការគ្រប់គ្រងអភិបាលកិច្ច និងការបណ្តុះបណ្តាលគ្រូនឹងត្រូវរៀបចំឡើង ដើម្បីធានាបាននូវសមត្ថភាពផ្នែកអប់រំបច្ចេកទេសដល់សិស្ស។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារ នឹងត្រូវបំពាក់ដើម្បីអនុវត្ត និងពិសោធន៍តាមលក្ខខណ្ឌតម្រូវក្នុងកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស ក្នុងគោលដៅធានាបាននូវគុណភាព និងនិរន្តរភាព ផ្នែកអប់រំបច្ចេកទេស។ ជាងនេះទៅទៀត ការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំបច្ចេកទេស នឹងផ្តោតលើសមត្ថភាពយេនឌ័រទាំងសិស្ស និងគ្រូបង្រៀននៅគ្រប់មុខជំនាញសិក្សាទាំងអស់។ បន្ថែមពីលើនេះ

ទៀត ការធានាគុណភាពកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស គឺសំដៅដល់ការផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពក្នុងក្របខណ្ឌបម្រែបម្រួលសង្គម វប្បធម៌ និងបរិស្ថាន។

## យុទ្ធសាស្ត្រទី១ ការបង្កើតក្របខណ្ឌគតិយុត្តគាំទ្រប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស

| យុទ្ធសាស្ត្រង១.១ ការកសាងលិខិតបទដ្ឋានគតិយុត្ត | |
|---|---|
| គោលបំណង | កសាង និងលើកកម្ពស់ការអប់រំបច្ចេកទេស ប្រកបដោយគុណភាព សុវត្ថិភាព ការច្នៃប្រឌិត សហគ្រិនភាព សហប្រតិបត្តិការ និងធានាបាននូវសមភាពយេនឌ័រ |
| លទ្ធផល | - ប្រកាស ស្តីពីការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស<br>- ប្រកាស ស្តីពីការកំណត់លក្ខណវិនិច្ឆ័យវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>- សេចក្តីណែនាំ ស្តីពីការដឹកនាំ និងគ្រប់គ្រងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>- សេចក្តីណែនាំ ស្តីពីការកំណត់លក្ខណវិនិច្ឆ័យគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស<br>- សេចក្តីណែនាំ ស្តីពីការអនុវត្តកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស<br>- សេចក្តីណែនាំ ស្តីពីកិច្ចសហប្រតិបត្តិការសាលារៀន និងវិស័យឯកជន<br>- សេចក្តីណែនាំ ស្តីពីភារកិច្ច និងសុវត្ថិភាពសាលារៀន<br>- សេចក្តីណែនាំ ស្តីពីការងាររដ្ឋបាលអធិការកិច្ច<br>- សេចក្តីណែនាំ ស្តីពីបទបញ្ញត្តិគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសក្នុងថ្នាក់<br>- សេចក្តីណែនាំ ស្តីពីការលើកទឹកចិត្តគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៥-២០១៦ |

| យុទ្ធសាស្ត្រង ១.២ ការបង្កើតយន្តការគ្រប់គ្រង និងការគាំទ្រ ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ផ្នែកអប់រំបច្ចេកទេស ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល |
| លទ្ធផល | – គណៈកម្មការសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឧស្សាហកម្ម<br>– គណៈកម្មការប្រឹក្សាអាជីពសម្រាប់សិស្ស |

| | |
|---|---|
| | – គណៈកម្មការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស<br>– គណៈកម្មការវាយតម្លៃ និងត្រួតពិនិត្យគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស<br>– គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេសក្នុងមុខជំនាញនីមួយៗ សម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស... |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា |
| អង្គភាពទទួលខុសត្រូវ | នា.តទវ  អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៥-២០១៦ |

| យុទ្ធសាស្ត្រវង ១.៣  ការបង្កើតផ្នែកស្រាវជ្រាវ និងការអភិវឌ្ឍ | |
|---|---|
| គោលបំណង | - ពង្រឹងការអប់រំបច្ចេកទេស ស្របតាមនិន្នាការវិវត្តផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>- បង្កើតការស្រាវជ្រាវ និងការអភិវឌ្ឍ ផ្នែកអប់រំបច្ចេកទេស ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយ ស្តីពីការអប់រំបច្ចេកទេស |
| លទ្ធផល | - នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នឹងត្រូវប្រែក្លាយទៅជានាយកដ្ឋានអប់រំបច្ចេកទេសនៅឆ្នាំ២០១៥<br>- ពង្រីក និងពង្រឹងការបណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស<br>- ការស្រាវជ្រាវ ស្តីពីការអប់រំបច្ចេកទេសនៅកម្ពុជា<br>- របាយការណ៍វិភាគ ស្តីពីបញ្ហាប្រឈម ការចំណាយ និងគុណប្រយោជន៍ នៃការអប់រំបច្ចេកទេស |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៨-២០១៩ |

## យុទ្ធសាស្ត្រទី២: ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស

ប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស




ប្រព័ន្ធអប់រំផ្លូវការនៃការអប់រំនៅមធ្យមសិក្សាទុតិយភូមិ នឹងត្រូវបង្កើតឡើងស្របតាមស្ថានភាពតម្រូវការរបស់សហគមន៍ រួមមានពីរផ្នែក គឺផ្នែកអប់រំចំណេះទូទៅ និងផ្នែកអប់រំបច្ចេកទេស។ ប្រព័ន្ធអប់រំនេះ បាន និងកំពុងអនុវត្តនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន៣។ ការចូលរៀនមុខវិជ្ជាអប់រំបច្ចេកទេស សិស្សត្រូវតែប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ទើបអាចដាក់ពាក្យចូលរៀនផ្នែកអប់រំបច្ចេកទេសបាន។ ការសិក្សាផ្នែកអប់រំបច្ចេកទេសមានរយៈពេល៣ឆ្នាំ អនុវត្តនៅមធ្យមសិក្សាទុតិយភូមិ គឺថ្នាក់ឆ្នាំទី១ ថ្នាក់ឆ្នាំទី២ និងថ្នាក់ឆ្នាំទី៣។ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស មានគោលដៅអប់រំសិស្សឲ្យមានជំនាញ និងសមត្ថភាព ប្រកបដោយចំណេះដឹងវិជ្ជាជីវៈពិតប្រាកដ និងចំណេះដឹងអាជីព ដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលដ៏លឿនក្នុងសង្គម ឧស្សាហកម្មដែលមាននិន្នាការទៅរកព័ត៌មានវិទ្យា។

| យុទ្ធសាស្ត្ររង ២.១ ការកែលម្អប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស | |
|---|---|
| គោលបំណង | កែលម្អប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស តាមរយៈការបង្កើតរចនាសម្ព័ន្ធអប់រំបច្ចេកទេស និងស្តង់ដារអប់រំបច្ចេកទេស |
| លទ្ធផល | - មានរចនាសម្ព័ន្ធការអប់រំបច្ចេកទេស តាមរយៈការកំណត់ស្តង់ដារមួយ អំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកម្មវិធីសិក្សា ផ្នែកអប់រំ |

| | |
|---|---|
| | បច្ចេកទេស<br>- មានស្តង់ដារសាលារៀន (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស សម្ភារបរិក្ខារ រោងជាង គ្រូបង្រៀន...) |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ (២០១៤-២០១៦) |
| អង្គភាពទទួលខុសត្រូវ | នា.តទវ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៥-២០១៨ |

| យុទ្ធសាស្ត្រវង ២.២ ការពង្រីក និងការពង្រឹងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | |
|---|---|
| គោលបំណង | - ពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដល់បណ្តារាជធានី-ខេត្ត ដែលមានសក្តានុពល<br>- បង្កើនការចុះឈ្មោះចូលរៀន នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>- ផ្តល់សេវាតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព |
| លទ្ធផល | – វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស មាននៅគ្រប់រាជធានី-ខេត្ត<br>– ចំនួនសិស្សចូលរៀន ផ្នែកអប់រំបច្ចេកទេសមានការកើនឡើង<br>– មានកម្មវិធីប្រឹក្សាអាជីព និងសេវាតម្រង់ទិសវិជ្ជាជីវៈ នៅគ្រប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ មន្ទីរ អយក. រាជធានី-ខេត្ត និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៥-២០១៦ |

| យុទ្ធសាស្ត្រវង ២.៣ ការគាំទ្រ និងដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | |
|---|---|
| គោលបំណង | - ផ្តល់ថវិកាដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>- ផ្តល់គ្រូឧទ្ទេស និងគ្រូជំនួយ សម្រាប់បង្រៀនមុខជំនាញបច្ចេកទេសនីមួយៗ នៅបន្ទប់ពិសោធន៍ និងរោងជាង |
| លទ្ធផល | - សាលារៀនមានថវិកាសម្រាប់ដំណើរការ<br>- មានគ្រូឧទ្ទេស និងគ្រូជំនួយគ្រប់មុខជំនាញដែលមានបទពិសោធន៍ច្រើន សម្រាប់ជំនាញនីមួយៗ នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស |

| | |
|---|---|
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ មន្ទីរ អយក.រាជធានី-ខេត្ត វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៥-២០១៨ |

## យុទ្ធសាស្ត្រទី៣ ការរៀបចំ និងការកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស

| យុទ្ធសាស្ត្រង ៣.១ ការរៀបចំ និងការកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | រៀបចំកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស ឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម |
| លទ្ធផល | - មានកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសលើជំនាញ មេកានិច អគ្គិសនី អេឡិចត្រូនិច ក្សេត្រសាស្ត្រ គណនេយ្យ និងជំនាញផ្សេងៗទៀតតាមតម្រូវការ<br>- មានសៀវភៅសិក្សាគោល ផ្នែកអប់រំបច្ចេកទេស តាមមុខវិជ្ជាជំនាញនីមួយៗសម្រាប់ថ្នាក់ឆ្នាំទី១ ថ្នាក់ឆ្នាំទី២ និងថ្នាក់ឆ្នាំទី៣ |
| ប្រភពថវិកា | ដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.គទវ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៥-២០១៦ |

| យុទ្ធសាស្ត្រង ៣.២ ការរៀបចំផែនការបង្រៀន និងរៀន ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | រៀបចំផែនការរៀន និងបង្រៀន ផ្នែកអប់រំបច្ចេកទេស |
| លទ្ធផល | មានផែនការបង្រៀន និងរៀនច្បាស់លាស់ពាក់ព័ន្ធនឹងការរៀនទ្រឹស្តី ប្រតិបត្តិ និងការវាយតម្លៃលទ្ធផលសិក្សា |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.គទវ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៦-២០១៧ |

| យុទ្ធសាស្ត្រង ៣.៣ ការពិនិត្យឡើងវិញជាប្រចាំនូវកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស ក្នុងគោលដៅធានានូវភាពច្នៃប្រឌិត ផ្នែកតាមបម្រែបម្រួលសង្គម | |
|---|---|
| គោលបំណង | ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស ទាក់ទងនឹងតម្រូវការទីផ្សារពលកម្ម និងបម្រែបម្រួលសង្គម |
| លទ្ធផល | - កម្មវិធីសិក្សាមួយមានភាពឆ្លើយតប និងភាពពាក់ព័ន្ធ<br>- មានបទបញ្ញត្តិ ស្តីពីការប្រមូលព័ត៌មានទាក់ទងនឹងការដឹកនាំ និងការគ្រប់គ្រងសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និង |

| | |
|---|---|
| | និន្នាការទីផ្សារការងារ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ  និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៦ |

## យុទ្ធសាស្ត្រទី៤ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបំពាក់សម្ភារបរិក្ខារ ផ្នែកអប់រំបច្ចេកទេស

| យុទ្ធសាស្ត្ររង ៤.១ ការសាងសង់បន្ទប់រៀន បន្ទប់ពិសោធន៍ និងអគាររោងជាង | |
|---|---|
| គោលបំណង | សាងសង់បន្ទប់រៀន អគាររោងជាង បន្ទប់ពិសោធន៍ ស្របតាមស្តង់ដារផ្នែកអប់រំបច្ចេកទេស |
| លទ្ធផល | - មានអគាររោងជាង បន្ទប់រៀន បន្ទប់ពិសោធន៍ ត្រូវតាមស្តង់ដារ<br>- មានសៀវភៅណែនាំ និងវិធានការ ស្តីពីការប្រើប្រាស់អគាររោងជាង បន្ទប់រៀន បន្ទប់ពិសោធន៍ និងទីធ្លាអនុវត្ត ដើម្បីធានាសុវត្ថិភាពអំឡុងពេលអនុវត្តនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៦-២០១៧ |

| យុទ្ធសាស្ត្ររង ៤.២ ការបំពាក់សម្ភារបរិក្ខារ ផ្នែកអប់រំបច្ចេកទេសស្របតាមស្តង់ដារតាមជំនាញនីមួយៗ | |
|---|---|
| គោលបំណង | ធានាថាបន្ទប់ពិសោធន៍ អគាររោងជាង បានបំពាក់សម្ភារបរិក្ខារស្របតាមស្តង់ដារជំនាញបច្ចេកទេសនីមួយៗ |
| លទ្ធផល | - សិស្សមានសម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់ប្រតិបត្តិតាមមុខជំនាញបច្ចេកទេសនីមួយៗ<br>- មានស្តង់ដារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារសម្រាប់ជំនាញអប់រំបច្ចេកទេសនីមួយៗ នៅថ្នាក់ជាតិ<br>- មានសៀវភៅណែនាំ ស្តីពីការថែទាំ ជួសជុល ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ អង្គភាពពាក់ព័ន្ធ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងដៃគូអភិវឌ្ឍ |
| ពេលវេលាគ្រោង | ២០១៦-២០១៨ |

## យុទ្ធសាស្ត្រទី៥ ការបណ្តុះបណ្តាលនិងការលើកកម្ពស់សមត្ថភាព និងគុណវុឌ្ឍិគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស

| យុទ្ធសាស្ត្ររង ៥.១ ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស និងមន្ត្រីគ្រប់គ្រង | |
|---|---|
| គោលបំណង | - បណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ប្រកបដោយគុណវុឌ្ឍិ និងសមត្ថភាព<br>- ពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកអប់រំបច្ចេកទេស |
| លទ្ធផល | - មន្ត្រីរដ្ឋបាលផ្នែកអប់រំបច្ចេកទេស មានសមត្ថភាពគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព<br>- គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស មានគុណវុឌ្ឍិសមស្របតាមនិយាមគោលការណ៍រៀន និងបង្រៀន<br>- មានគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ប្រកបដោយវិជ្ជាជីវៈសម្រាប់មុខជំនាញនីមួយៗ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៨ |

| យុទ្ធសាស្ត្ររង ៥.២ ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | - រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស<br>- បណ្តុះបណ្តាល និងរិក្រឹតការគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស តាមមុខជំនាញមួយច្បាស់លាស់ |
| លទ្ធផល | - កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសផ្សារភ្ជាប់នឹងសហគ្រាស<br>- សៀវភៅណែនាំ ស្តីពីការប្រើប្រាស់កម្មវិធីបណ្តុះបណ្តាល<br>- សៀវភៅវិធីសាស្ត្របង្រៀន និងរៀនដោយច្នៃប្រឌិត |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៨ |

| យុទ្ធសាស្ត្ររង ៥.៣ ការលើកទឹកចិត្តគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | - រៀបចំប្រព័ន្ធលើកទឹកចិត្ត ដើម្បីទាក់ទាញគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសឲ្យបង្រៀននៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>- លើកទឹកចិត្តសិស្សដែលបានបញ្ចប់ការសិក្សាផ្នែកអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ មានលំដាប់និទ្ទេស A និង B ឲ្យចូលក្របខណ្ឌគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសដោយស្វ័យប្រវត្តិ<br>- លើកទឹកចិត្តបុគ្គលិកបម្រើនៅក្នុងក្រុមហ៊ុនឯកជន ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ និងបទពិសោធន៍ជំនាញច្បាស់លាស់ឲ្យចូលក្របខណ្ឌគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស តាមរយៈកិច្ចសន្យា ឬឆ្លងកាត់ការប្រឡងជ្រើសរើស |
| លទ្ធផល | - មានប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស<br>- មានគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេសប្រកបដោយគុណវុឌ្ឍិគ្រប់គ្រាន់ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.គទវ និងអង្គភាពពាក់ព័ន្ធ |
| ពេលវេលាគ្រោង | ២០១៨ |

## យុទ្ធសាស្ត្រទី៦ ការទទួលស្គាល់ និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស

| យុទ្ធសាស្ត្រទង៦.១ ការកសាងប្រព័ន្ធទទួលស្គាល់ និងការធានាគុណភាព ផ្នែកអប់រំបច្ចេកទេស | |
|---|---|
| គោលបំណង | លើកកម្ពស់សុខដុមនីយកម្មរវាងគោលនយោបាយ ការធ្វើសេចក្តីសម្រេច លិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធដល់ការអនុវត្ត |
| លទ្ធផល | - មានរចនាសម្ព័ន្ធ និងប្រព័ន្ធធានាគុណភាព ផ្នែកអប់រំបច្ចេកទេស នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ពីថ្នាក់ជាតិដល់ថ្នាក់ជាតិក្រោម<br>- មានលិខិតបទដ្ឋានគតិយុត្ត ស្តីពីតួនាទី និងទំនួលខុសត្រូវ របស់គណៈកម្មការ/អង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ប្រភពថវិកា | ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ |
| អង្គភាពទទួលខុសត្រូវ | នា.តទវ មន្ទីរ អយក. និងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស |
| ពេលវេលាគ្រោង | ២០១៧ |

| យុទ្ធសាស្ត្រង ៦.២ ការទទួលស្គាល់ និងគុណវុឌ្ឍិសិស្ស | |
|---|---|
| គោលបំណង | - បង្កឱកាស និងលើកកម្ពស់សមត្ថភាពសិស្ស ដើម្បីបន្តការសិក្សាទៅកម្រិតឧត្តមសិក្សា ឬធ្វើការងារ<br>- ធ្វើឲ្យសង្គមទទួលស្គាល់ការអប់រំបច្ចេកទេសប្រសើរជាងមុន ដើម្បីទាក់ទាញការចូលរួមរបស់សិស្ស និងគ្រូ |
